# ឥទ្ធិពលនៃការចូលរួមរបស់អ្នកស្រុកទៅលើទស្សនៈ និងការគាំទ្រដល់សហគមន៍អេកូទេសចរណ៍នៅកម្ពុជា៖ វិធីសាស្ត្រ ម៉ូដែលសមីការជាប្រព័ន្ធ

## សេចក្ដីផ្ដើម

អ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តជាក់ស្ដែង បានទទួលស្គាល់ជាយូរមកហើយថា ឥរិយាបថ និងការចូលរួមរបស់អ្នកស្រុក ជាកត្តាគន្លឹះពីរដែលជះឥទ្ធិពលដល់ជោគជ័យ និងចីរភាពនៃការអភិវឌ្ឍទេសចរណ៍។ អេកូទេសចរណ៍ផ្អែកលើសហគមន៍ (CBET) ត្រូវបានគេផ្ដួចផ្ដើមគំនិត និងអនុវត្តនៅកម្ពុជា តាំងពីដើមទសវត្សរ៍១៩៩០ ក្នុងទម្រង់ជា គម្រោងដាក់បញ្ចូលគ្នានូវការអភិរក្ស និងអភិវឌ្ឍន៍ (integrated conservation and development projects: ICDPs) ដើម្បីថែរក្សាធនធានធម្មជាតិ និងបង្កើតចំណូលបន្ថែមសម្រាប់ប្រជាជនមូលដ្ឋាន។ ថ្វីបើគម្រោងអេកូទេសចរណ៍ផ្អែកលើសហគមន៍ ជាច្រើនមានជោគជ័យ និងចីរភាពល្អក្ដី ប៉ុន្តែក៏មានច្រើនដែរ ដែលមិនអាចបន្តដំណើរការបានយូរអង្វែង។ កត្តាកំណត់មួយនៃបរាជ័យនេះ អាចជាការចូលរួមកម្រិតទាប ឬមិនចូលរួម និងឥរិយាបថអវិជ្ជមានរបស់អ្នកស្រុក។ Carter et al. (2015) បានរកឃើញថា ២៣% នៃការសិក្សាមុនៗ និងឯកសារមានស្រាប់ស្ដីពីទេសចរណ៍មានចីរភាពនៅកម្ពុជា ផ្ដោតលើអេកូទេសចរណ៍។ ប៉ុន្តែក្នុងនេះ ឥរិយាបថរបស់អ្នកស្រុកចំពោះ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ហើយនិង ទំនាក់ទំនងរវាងការចូលរួម ជាមួយនឹងឥរិយាបថរបស់អ្នកស្រុក នៅមានការសិក្សាតិចតួចណាស់នៅកម្ពុជា។ ដូច្នេះ ដើម្បីបានយល់ដឹងកាន់តែប្រសើរ ពីតួនាទីនៃការចូលរួមរបស់អ្នកស្រុកក្នុងការកែលំអឥរិយាបថរបស់ខ្លួន ចំពោះអេកូទេសចរណ៍ផ្អែកលើសហគមន៍ ការសិក្សានេះព្យាយាមកំណត់ពី ឥទ្ធិពលនៃការចូលរួមរបស់អ្នកស្រុកទៅលើទស្សនៈ និងការគាំទ្ររបស់គាត់ដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។

## ក្របខ័ណ្ឌគោលគំនិត

ក្រុមស្រាវជ្រាវបានប្រើប្រាស់ ម៉ូដែលសមីការជាប្រព័ន្ធ (structural equation modelling: SEM) ដើម្បីសិក្សាពីទំនាក់ទំនងរវាងកត្តាជាប់ពាក់ព័ន្ធនានា ដូចមានបង្ហាញក្នុងរូបភាព A1 នៃឧបសម្ព័ន្ធ។ ពីដំបូង ក្រុមស្រាវជ្រាវបានបង្កើតសម្មតិកម្មមួយសំណុំ ដោយផ្អែកលើការសិក្សាមុនៗនិងឯកសារមានស្រាប់ និងទ្រឹស្ដីសំខាន់ៗមួយចំនួន។ សម្មតិកម្មទាំងនោះមានបញ្ជាក់នៅខាងក្រោម។

## ការចូលរួមដោយមានកម្រៃ

នៅក្នុងអេកូទេសចរណ៍ផ្អែកលើសហគមន៍ តាមធម្មតាគេប្រើការចូលរួមដោយមានកម្រៃ (remunerative participation: RPART) ជាមធ្យោបាយលើកទឹកចិត្ត សម្រាប់ជំរុញអ្នកស្រុកឲ្យចូលរួមក្នុង អេកូទេសចរណ៍ផ្អែកលើសហគមន៍ ដើម្បីជួយថែរក្សាធនធានធម្មជាតិ និងជួយគាំទ្រដល់គម្រោង អេកូទេសចរណ៍ផ្អែកលើសហគមន៍។ RPART វាស្រដៀងគ្នានឹង ការពឹងផ្អែកផ្នែកសេដ្ឋកិច្ចរបស់អ្នកស្រុកទៅលើទេសចរណ៍ និងជាកត្តាមួយដែលមានគេសិក្សាច្រើន។ កម្រិតនៃ RPART គឺអាចដូចគ្នានឹងកម្រិតនៃការពឹងផ្អែកទៅលើទេសចរណ៍។ គេអាចមើលឃើញយ៉ាងងាយថា អ្នកស្រុកដែលមានការពឹងផ្អែកផ្នែកសេដ្ឋកិច្ចទៅលើទេសចរណ៍ អាចមានឥរិយាបថវិជ្ជមានចំពោះការអភិវឌ្ឍទេសចរណ៍។ ការសិក្សារបស់ Pizam (1978) and Vesey and Dimanche (2000) បានគាំទ្រដល់មតិនេះ។ ដោយផ្អែកលើការសិក្សាទាំងនោះ និងមតិផ្ទាល់របស់ក្រុមស្រាវជ្រាវ ក្រុមស្រាវជ្រាវបានលើកជា សម្មតិកម្ម ៤ ឡើង៖

H1. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ការចូលរួមដោយគ្មានកម្រៃ (non- remunerative participation: NRPART)។

H2. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ទស្សនៈពីផលប៉ះពាល់នៃអេកូទេសចរណ៍ទៅលើ ទ្រព្យទ្រទ្រង់ជីវភាព (perceived impacts on livelihood assets: PILA)។

H3. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ទស្សនៈពីផលប៉ះពាល់នៃអេកូទេសចរណ៍ទៅលើ កម្រិតជីវភាព (perceived impacts on livelihood outcome: PILO)។

H4. RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ ការគាំទ្រចំពោះអេកូទេសចរណ៍ (support for CBET: SUPPORT)។

## ការចូលរួមដោយគ្មានកម្រៃ

ការសិក្សាជាច្រើនបានរកឃើញថា ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍ ការគ្រប់គ្រង ឬការធ្វើសេចក្ដីសម្រេចចិត្ត វាជះឥទ្ធិពលវិជ្ជមានទៅលើទស្សនៈ ពីផលប៉ះពាល់នៃទេសចរណ៍។ Lankford (1994) បានលើកគំនិតថា បើសិនមានការគិតគូរដល់មតិយោបល់ និងការចូលរួមរបស់អ្នកស្រុក ពួកគាត់ទំនងជួយគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍។ គំនិតនេះមានការគាំទ្រពី Lee (2013) ដែលបង្ហាញថា ការចូលរួមរបស់សហគមន៍

---

អត្ថបទនេះរៀបរៀងដោយ វ៉ែន សីហា ជាអ្នកស្រាវជ្រាវក្នុងផ្នែកសេដ្ឋកិច្ចនៃវិទ្យាស្ថាន CDRI និង Koichi Usami ជាសាស្ត្រាចារ្យនៅ Graduate School of International Development, Nagoya University, Japan។
សូមយោងឯកសារនេះថា៖ Ven Seyhah and Koichi Usami. 2017. "The Effects of Residents' Participation on Their Perception of and Support for Community-Based Ecotourism in Cambodia: A Structural Equation Modeling Approach." *Cambodia Development Review* 21 (1): 8-13.

រូបភាព ១៖ ម៉ូដែលតាមទ្រឹស្ដី




ប្រភព៖ ការសិក្សារបស់អ្នកនិពន្ធលើឯកសារមានស្រាប់
កំណត់សំគាល់៖ H មានន័យថា សម្មតិកម្ម

វាជាប់ទាក់ទងជាវិជ្ជមានជាមួយនឹង ការគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍។ ដោយផ្អែកលើការសិក្សាមុនៗ និងឯកសារមានស្រាប់ទាំងនេះ ក្រុមស្រាវជ្រាវបានលើកជាសម្មតិកម្មដូចខាងក្រោម៖

H5. NRPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILA។
H6. NRPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILO។
H7. NRPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។

### ផលប៉ះពាល់តាមទស្សនៈរបស់អ្នកស្រុក

ការសិក្សាភាគច្រើនក្នុងពេលកន្លងមក បានវាយតម្លៃពីផលប៉ះពាល់តាមទស្សនៈរបស់អ្នកស្រុក ដោយផ្អែកលើទិដ្ឋភាពសេដ្ឋកិច្ច សង្គម និង បរិស្ថាន។ គួរកត់សំគាល់ថា សូចនាករទាំងនេះ វាសមស្របសម្រាប់ការវាយតម្លៃលើតំបន់ទេសចរណ៍ខ្នាតធំ។ ប៉ុន្តែការសិក្សានេះផ្តោតលើ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ដែលគ្រប់គ្រងដោយប្រជាជនក្នុងមូលដ្ឋាន និងជារឿយៗមានជំនួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផង។ អេកូទេសចរណ៍ផ្អែកលើសហគមន៍ មានគោលដៅជួយលើកស្ទួយជីវភាពប្រជាជន និងថែរក្សាធនធានធម្មជាតិក្នុងមូលដ្ឋាន។ ដូច្នេះហើយ ការសិក្សានេះក៏បានពិនិត្យពីផលប៉ះពាល់នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ យោងតាមទស្សនៈរបស់អ្នកស្រុកទៅលើ ទ្រព្យទ្រទ្រង់ជីវភាព (PILA) និង កម្រិតជីវភាព (PILO)។ ទ្រព្យទ្រទ្រង់ជីវភាព រួមមាន ទ្រព្យស្នូល ៥ ប្រភេទ ដែលជីវភាពប្រជាជនត្រូវពឹងផ្អែកលើវា។ ដោយឡែក កម្រិតជីវភាព គឺជាលទ្ធផលនៃសកម្មភាពដោះស្រាយជីវភាព និងមានទម្រង់ជា កំណើនប្រាក់ចំណូល កំណើនសុខមាលភាព ការថយចុះភាពងាយរងគ្រោះ ការកែលំអសន្តិសុខស្បៀង និងការប្រើប្រាស់កាន់តែមានចីរភាពនូវ មូលដ្ឋានធនធានធម្មជាតិ (DFID 1999)។ ដោយសារទ្រព្យទ្រទ្រង់ជីវភាព វាជាគ្រឹះដើម្បីសម្រេចបាន កម្រិតជីវភាពល្អប្រសើរ ដូច្នេះ PILA ទំនងជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILO។

ទ្រឹស្ដីនៃ ការដោះដូរគ្នាក្នុងសង្គម (social exchange theory: SET) កន្លងមក គេបានយកមកប្រើយ៉ាងទំលំទូលាយក្នុងការសិក្សាពីឥរិយាបថរបស់អ្នកស្រុក ចំពោះការអភិវឌ្ឍទេសចរណ៍។ SET អះអាងថា បើសិនអ្នកស្រុក មានទស្សនៈថា ទេសចរណ៍មាន ផលប៉ះពាល់វិជ្ជមាន មិនមែនផលប៉ះពាល់អាក្រក់ ដែលមិនអាចទទួលយកបានទេនោះ ពួកគាត់ទំនងជាជួយគាំទ្រវា។ ផ្អែកលើការអះអាងនេះ អ្នកសិក្សាស្រាវជ្រាវជាច្រើននាក់ បានរកឃើញថា ផលប៉ះពាល់តាម ទស្សនៈរបស់អ្នកស្រុក គឺជាដើមចមនៃការគាំទ្រដល់ ការអភិវឌ្ឍទេសចរណ៍។ ដូច្នេះ គេអាចបង្កើតជាសម្មតិកម្មដូចតទៅ៖

H8. PILA ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ PILO។
H9. PILA ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។
H10. PILO ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។

សម្មតិកម្ម H1 និង H7 ចែងថា RPART ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ NRPART ដែលបន្ទាប់មកក៏ជះឥទ្ធិពលដោយផ្ទាល់ និងវិជ្ជមានដល់ SUPPORT។ តាមនេះ RPART ទំនងជះឥទ្ធិពលដោយប្រយោល និងវិជ្ជមានដល់ SUPPORT ដោយមាន NRPART ជាកត្តាជួយសម្រួល (H11)[1]។ ស្រដៀងគ្នាដែរ ផ្អែកតាមសម្មតិកម្មផ្សេងៗទៀត គឺទំនងជា RPART និង NRPART ជះឥទ្ធិពលដោយប្រយោល និងវិជ្ជមានដល់ SUPPORT ដោយមាន PILA និង PILO ជាកត្តាជួយសម្រួល (H11 និង H13)។

### វិធីសាស្ត្រសិក្សា

#### តំបន់សិក្សា

ការសិក្សានេះបានធ្វើឡើងនៅឃុំជីផាត់ ក្នុងតំបន់ព្រៃការពារភ្នំក្រវាញភាគខាងត្បូង ក្នុងខេត្តកោះកុង។ យោងតាមមូលដ្ឋានទិន្នន័យរបស់ឃុំ នៅឆ្នាំ២០១០ ឃុំជីផាត់មានប្រជាជនសរុប ៥៤៩ គ្រួសារ ក្នុងនោះ ៦៩% មានមុខរបរចម្បងដាំដុះស្រូវ, ១៣% មានមុខរបរចម្បងដាំដំណាំផ្សេងៗនិងបន្លែ ធ្វើនេសាទ និងចិញ្ចឹមសត្វ, ហើយ ៤,១% ប្រមូលអនុផលព្រៃឈើ។ សហគមន៍អេកូទេសចរណ៍ជីផាត់ បានកកើតឡើងក្នុងឆ្នាំ២០០៧ ដោយមានជំនួយគាំទ្រពីអង្គការ Wildlife Alliance (សម្ព័ន្ធភាពការពារសត្វព្រៃ) ដើម្បីការពារធនធានធម្មជាតិក្នុងមូលដ្ឋាន និងកែលំអជីវភាពរស់នៅរបស់អ្នកស្រុក។ អេកូទេសចរណ៍ផ្អែកលើសហគមន៍ មានគណៈកម្មាធិការគ្រប់គ្រងមួយជ្រើសតាំងឡើងតាមការបោះឆ្នោត និងមានសមាជិកចំនួន ១៦៧គ្រួសារ ដែល

1 ឥទ្ធិពលដោយប្រយោលនៃ (H11, H12, H13) មិនអាចបង្ហាញក្នុង រូបភាព១ បានទេ ព្រោះផ្លូវរបស់វាត្រូវបានបាំងជិតអស់ដោយឥទ្ធិពលដោយផ្ទាល់។

រូបភាព ២៖ ម៉ូដែលផ្ទៀងផ្ទាត់




ប្រភព៖ លទ្ធផលនៃការវិភាគរបស់អ្នកនិពន្ធ ឆ្នាំ២០១៤
កំណត់សំគាល់៖ ( ) denotes standardised coefficients; significant at p-value < 0.01*** and <0.05 **.

ផ្លាស់វេនគ្នាផ្ដល់សេវាឲ្យទេសចរ ដូចជា ការស្នាក់តាមផ្ទះអ្នកភូមិ ផ្ទះសំណាក់ មគ្គុទ្ទេសន៍ ការដឹកជញ្ជូន ម្ហូបអាហារ ជាដើម។

## ការប្រមូលទិន្នន័យ

ទិន្នន័យបានប្រមូលយកពីអ្នកស្រុក ២០០នាក់ ក្នុង ៤ភូមិ នៅឃុំជីផាត់ ដែលមានទាំងសមាជិក និងអ្នកមិនមែនសមាជិកនៃសហគមន៍អេកូទេសចរណ៍ជីផាត់។ អង្កេតបានធ្វើឡើងក្នុងខែឧសភា ២០១៤ ដោយប្រើបញ្ជីសំណួររៀបរយសម្រាប់ធ្វើសម្ភាសន៍។ សំណាកត្រូវបានជ្រើសយកតាមវិធីរើសសំណាកសមាមាត្រ (proportionate sampling) ដើម្បីបានអ្នកឆ្លើយសម្ភាសន៍ចម្រុះគ្នា ពីក្នុងភូមិទាំង ៤។

## ការវិភាគទិន្នន័យ

ម៉ូដែលសមីការជាប្រព័ន្ធ (structural equation modelling: SEM) ដែលមានពីរជំហាន ត្រូវបានបង្កើតឡើង ដើម្បីធ្វើតេស្តម៉ូដែលតាមទ្រឹស្ដី (theoretical model) ដូចមានបង្ហាញក្នុង Figure A1 នៃឧបសម្ព័ន្ធ។ ជំហានទី១ គឺ ការបង្កើតម៉ូដែលវាស់វែង (measurement model) ដើម្បីផ្ទៀងផ្ទាត់មើលថា សូចនាករ (observed variables) ពិតជាវង្វាស់សមរម្យសម្រាប់អញ្ញាតអរូបិយ (latent variable) របស់ពួកវាមែន។ វិធីសាស្ត្រវិភាគកត្តាបញ្ជាក់ (confirmatory factor analysis: CFA) បានយកមកអនុវត្ត ដើម្បីធ្វើតេស្តបញ្ជាក់ពីភាពស៊ីគ្នាល្អ (fitness) នៃម៉ូដែលវាស់វែង ដែលក្នុងនោះ អញ្ញាតអរូបិយទាំង ៥ (គឺមាន RPART, NRPART, PILA, PILO, SUPPORT) ត្រូវបានសន្មតថា មានទំនាក់ទំនងជាមួយគ្នា។ ភាពអាចទុកចិត្តបាន (reliability) និងសុពលភាព (validity) នៃអញ្ញាតអរូបិយ ក៏ត្រូវបានត្រួតពិនិត្យដែរ។ ជំហានទី២ ក្នុង SEM គឺ ការធ្វើតេស្តបញ្ជាក់លើសម្មតិកម្មស្ដីពី ទំនាក់ទំនងជាប្រព័ន្ធរវាងអញ្ញាតអរូបិយទាំង ៥។ ម៉ូដែលទំនាក់ទំនងជាប្រព័ន្ធ (structural model) វាប្រហាក់ប្រហែលគ្នានឹង ordinary least squares regression ដែរ។ ទំនាក់ទំនងណាមិនមានសារៈសំខាន់ គឺត្រូវដកចេញពីម៉ូដែល ហើយសម្មតិកម្មជាប់ពាក់ព័ន្ធនឹងវាក៏ត្រូវទាត់ចោលដែរ។ កម្មវិធីកុំព្យូទ័រសម្រាប់វិភាគ Mplus version 6.12 ដោយប្រើ maximum likelihood with robust standard error (MLR) estimator ត្រូវបានយកមកប្រើ ក្នុងជំហានទាំង ២។ MLR នេះគេតែងផ្ដល់មតិឲ្យយកមកប្រើសម្រាប់ ទិន្នន័យមិនមាន normality distribution និង មានសំណាកទំហំតូច។

## លទ្ធផល និងការពិភាក្សា

### ឥទ្ធិពលនៃការចូលរួមដោយមានកម្រៃ

ការវិភាគ ផ្ដល់លទ្ធផលថា ការចូលរួមដោយមានកម្រៃ ជះឥទ្ធិពលវិជ្ជមានខ្លាំងទៅលើ ការចូលរួមដោយគ្មានកម្រៃ ដូចបានចែងក្នុងសម្មតិកម្ម។ ពិតហើយ អ្នកស្រុកដែលមានការចូលរួមដោយមានកម្រៃ តែងត្រូវមានការចូលរួមដោយគ្មានកម្រៃផងដែរ ដូចជាក្នុងការប្រជុំការបណ្ដុះបណ្ដាល និងសកម្មភាពអភិរក្សផ្សេងៗ។ តាមនេះ ការចូលរួមដោយមានកម្រៃ ដើរតួនាទីសំខាន់ក្នុងការជំរុញអ្នកស្រុកឲ្យចូលរួមក្នុងការអភិវឌ្ឍ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ដូចមានពិភាក្សានៅខាងដើម ការចូលរួមដោយមានកម្រៃជាទូទៅគេប្រើវាជាគ្រឿងលើកទឹកចិត្តឲ្យ អ្នកស្រុកជួយគាំទ្រដល់គម្រោង អេកូទេសចរណ៍ផ្អែកលើសហគមន៍។

លទ្ធផលបង្ហាញច្បាស់ថា ការចូលរួមដោយមានកម្រៃមានចំណែកតិចតួចណាស់ ក្នុងការជំរុញឲ្យអ្នកស្រុកមានទស្សនៈវិជ្ជមានពីផលប៉ះពាល់នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ហើយជួយគាំទ្រវា។ ការវិភាគផ្ដល់គំនិតថា អ្នកស្រុកគ្រប់គ្នាទោះមានការចូលរួមដោយមានកម្រៃកម្រិតណាក្ដី គឺតែងមានទស្សនៈល្អពី ផលប៉ះពាល់នៃអេកូទេសចរណ៍ផ្អែកលើសហគមន៍ និងជួយគាំទ្រវាក្នុងកម្រិតប្រហែលគ្នា។ ចំណុចនេះអាចមានន័យថា ទស្សនៈល្អរបស់អ្នកស្រុកពីផលប៉ះពាល់នៃ អេកូទេសចរណ៍

ផ្អែកលើសហគមន៍ និងការជួយគាំទ្រវា ទំនងទទួលឥទ្ធិពលខ្លាំងជាងពីកត្តាផ្សេងទៀត ដូចជា បំណងចង់បានការអភិវឌ្ឍសេដ្ឋកិច្ចបន្ថែម ជាដើម (Campbell 1999; Lepp 2007)។ អាចមានហេតុផលមួយទៀតថា អ្នកស្រុកមានការចូលរួមដោយមានកម្រៃកម្រិតទាប តែមានឥរិយាបថវិជ្ជមាន និងការគាំទ្រខ្លាំងដល់ការអភិវឌ្ឍទេសចរណ៍ ដោយសារគាត់ជឿជាក់លើឥទ្ធិពលដោយប្រយោល (trickle-down effects) នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ពោលគឺ គាត់អាចយល់ឃើញថា អេកូទេសចរណ៍ផ្អែកលើសហគមន៍ ជួយលើកស្ទួយដោយផ្ទាល់នូវជីវភាពរបស់អ្នកស្រុកមួយក្រុម ដូច្នេះ វានឹងជួយកែលំអដោយប្រយោលតាមបែបបទណាមួយនូវជីវភាពរបស់អ្នកស្រុកឯទៀតដែរ។

## ឥទ្ធិពលនៃការចូលរួមដោយគ្មានកម្រៃ

ស្រដៀងគ្នានឹងការចូលរួមដោយមានកម្រៃដែរ លទ្ធផលវិភាគបង្ហាញថា ការចូលរួមដោយគ្មានកម្រៃមិនមានតួនាទីអ្វីគួរឲ្យកត់សំគាល់ទេ ក្នុងការបង្កើនទស្សនៈវិជ្ជមានលើការអភិវឌ្ឍទេសចរណ៍។ លទ្ធផលនេះស្រដៀងគ្នានឹងការសិក្សាដែល Nicholas, Thapa and Ko (2009) បានរាយការណ៍ឡើងថា ការចូលរួមរបស់សហគមន៍ មិនមានទំនាក់ទំនងអ្វីគួរឲ្យកត់សំគាល់ទេ ជាមួយនឹងទស្សនៈស្ដីពីទេសចរណ៍មានចីរភាព។ ប៉ុន្តែការចូលរួមដោយគ្មានកម្រៃ មានទំនាក់ទំនងដោយផ្ទាល់ និងវិជ្ជមាន ជាមួយនឹង ការគាំទ្រ។ វាជាទំនាក់ទំនងខ្សោយក៏ពិតមែន ប៉ុន្តែអាចជួយគាំទ្រដល់ Lankford (1994) ដែលអះអាងថា បើសិនអ្នកស្រុកដឹងថា មានការគិតគូរដល់មតិយោបល់ និងផលប្រយោជន៍របស់គាត់នោះ គាត់កាន់តែទំនងជួយគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍។ ការអះអាងនេះស្របគ្នានឹង ការរកឃើញរបស់ Lee (2013) ដែរ។ ផ្អែកលើលទ្ធផលទាំងនេះ គេអាចសន្និដ្ឋានថា អ្នកស្រុកដែលបានចូលរួមក្នុងការបណ្ដុះបណ្ដាលរបស់ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ឬបានបញ្ចេញមតិក្នុងការប្រជុំពី អេកូទេសចរណ៍ផ្អែកលើសហគមន៍ តែងជួយគាំទ្រដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ក្នុងកម្រិតខ្ពស់ជាង អ្នកមិនមានការចូលរួមដោយគ្មានកម្រៃ ពីព្រោះឆ្លងតាមការចូលរួមដោយគ្មានកម្រៃ អ្នកស្រុកអាចមានព័ត៌មានច្បាស់ជាង និងបានដឹងពីបំណងល្អ ស្ថានភាពពិត និងផលប្រយោជន៍នៃគម្រោងអេកូទេសចរណ៍ផ្អែកលើសហគមន៍ ហើយតាមនេះ អាចកាន់តែមានការយោគយល់ និងជឿទុកចិត្តលើ អេកូទេសចរណ៍ផ្អែកលើសហគមន៍ និងផលប៉ះពាល់របស់វា។

លទ្ធផលរកឃើញផ្ដល់គំនិតទៀតថា អ្នកស្រុកដែលបានចូលរួមដោយមានកម្រៃ និងចូលរួមដោយគ្មានកម្រៃ តែងមានទស្សនៈវិជ្ជមានលើផលប៉ះពាល់នៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍ និងការគាំទ្រដល់ទេសចរណ៍ប្រភេទនេះ ក្នុងកម្រិតខ្ពស់បន្តិចជាង អ្នកគ្រាន់តែបានចូលរួមដោយមានកម្រៃតែម្យ៉ាង។ ដូច្នេះគេអាចសន្និដ្ឋានបានថា ការចូលរួមដោយមានកម្រៃ គួបផ្សំនឹង ការចូលរួមដោយគ្មានកម្រៃ អាចជាវិធីសាស្ត្រមានប្រសិទ្ធភាពល្អ ដើម្បីទទួលបានការគាំទ្រពីអ្នកស្រុកដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។

លទ្ធផលរកឃើញបានបញ្ជាក់គាំទ្រដល់ មូលដ្ឋានគ្រឹះនៃទ្រឹស្ដីនៃការដោះដូរគ្នាក្នុងសង្គម (social exchange theory) និងលទ្ធផលនៃការសិក្សាពីមុនៗ ពោលគឺ អ្នកស្រុកដែលជឿទុកចិត្តថា អេកូទេសចរណ៍ផ្អែកលើសហគមន៍ ជួយបង្កើនទ្រព្យទ្រទ្រង់ជីវភាព និងជួយលើកស្ទួយកម្រិតជីវភាព គឺច្រើនតែជួយគាំទ្រវា។

## សេចក្ដីសន្និដ្ឋាន

លទ្ធផលរកឃើញបង្ហាញថា ការចូលរួមដោយមានកម្រៃ មានតួនាទីគួរឲ្យកត់សំគាល់ ក្នុងការលើកទឹកចិត្តអ្នកស្រុកឲ្យចូលរួមក្នុងសកម្មភាពគ្មានកម្រៃនៃ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ទោះយ៉ាងនេះក្ដី ការចូលរួមដោយមានកម្រៃមិនមានតួនាទីអ្វីសំខាន់ទេ ក្នុងការជំរុញឲ្យអ្នកស្រុកកាន់តែមានទស្សនៈល្អពីផលប៉ះពាល់ និងជួយគាំទ្រដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ស្រដៀងគ្នាដែរ ការចូលរួមដោយគ្មានកម្រៃក្នុង អេកូទេសចរណ៍ផ្អែកលើសហគមន៍ មិនមានឥទ្ធិពលអ្វីគួរឲ្យកត់សំគាល់ទេទៅលើទស្សនៈពីផលប៉ះពាល់។ ប៉ុន្តែ ការចូលរួមដោយគ្មានកម្រៃជះឥទ្ធិពលវិជ្ជមាន ទៅលើការគាំទ្ររបស់អ្នកស្រុកដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។ ម្យ៉ាងទៀត ការចូលរួមដោយមានកម្រៃ វាជះឥទ្ធិពលវិជ្ជមានដោយប្រយោលទៅលើការគាំទ្រដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍ ឆ្លងតាមការចូលរួមដោយគ្មានកម្រៃ។ ចំណុចនេះផ្ដល់គំនិតថា ការចូលរួមដោយមានកម្រៃ គួបផ្សំនឹង ការចូលរួមដោយគ្មានកម្រៃ គឺជាវិធីសាស្ត្រមានប្រសិទ្ធភាពល្អ ដើម្បីឲ្យមានការគាំទ្រពីអ្នកស្រុកដល់ អេកូទេសចរណ៍ផ្អែកលើសហគមន៍។

## ឯកសារយោង

Campbell, Lisa M. 1999. “Ecotourism in Rural Developing Communities.” *Annals of Tourism Research* 26 (3): 534–553.

Carter, R. W. (Bill), Thok Sokhom, Vicky O’Rourke and Tristan Pearce. 2015. “Sustainable Tourism and its Use as a Development Strategy in Cambodia: A Systematic Literature Review.” *Journal of Sustainable Tourism* 23 (5): 797–818.

DFID (Department for International Development). 1999. “Sustainable Livelihoods Guidance Sheets.” http://www.eldis.org/vfile/upload/1/document/0901/section2.pdf.

Lankford, Samuel V. 1994. “Attitudes and Perceptions Toward Tourism and Rural Regional Development.” *Journal of Travel Research* 32 (3): 35–43.

Lee, T. H. 2013. “Influence Analysis of Community Resident Support for Sustainable Tourism Development.” *Tourism Management* 34: 37–46.

Lepp, Andrew. 2007. “Residents’ Attitudes Towards Tourism in Bigodi Village, Uganda.” *Tourism Management* 28 (3): 876–885.

*តទៅទំព័រ ១៤*

Woosnam, Kyle M. 2012. "Using Emotional Solidarity to Explain Residents' Attitudes about Tourism and Tourism Development." *Journal of Travel Research* 51 (3): 315–327.

**Appendix: Structural Equation Modelling**

***Model specification***

Structural equation modelling (SEM) was used to explain the structural relationships between the factors of interest. Figure A1 illustrates the structural paths based on the hypotheses posited in the section on structural framework.

Figure A1: Theoretical model




RPART, NRPART, PILA, PILO and SUPPORT are latent variables, which were measured with respective sets of observed variables. RPART and NRPART are the self-reported frequencies of residents' remunerative and non-remunerative participation in CBET. The observed variables of PILA and PILO were created based on the Sustainable Livelihoods Guidance Sheet of the UK's Department for International Development (DFID 1999). Support for CBET was adopted from Woosnam's (2012) modified Tourism Impact Attitude Scale. The questions were rated on the seven-point Likert scale, where one designates never (for RPART and NRPART), extremely negative (for PILA and PILO) and strongly disagree (for SUPPORT), while seven represents extremely often (for RPART and NRPART), or extremely positive (for PILA and PILO) and strongly agree (for SUPPORT).

***Model selection***

Table A1 presents the model fit statistics for the measurement model, theoretical structural model and verified structural model.

***Measurement model***

Table A1 shows that the measurement model has a significant chi square ($\chi 2 = 202$, df = 122, p-value < 0.001), suggesting that it was a poor fit for the data. However, chi square is likely to be significant when the sample is large, so it is recommended that researchers use alternative fit indices in addition to chi square. One of them is the ratio of $\chi 2$/df, for which the cut-off value

Table A1: Model fit statistics

| Model Fit Index | Measurement Model | Structural Model | |
|---|---|---|---|
| | | Theoretical | Verified |
| **Absolute fit indices** | | | |
| Chi square | 201.64 | 201.64 | 204.42 |
| df | 122.00 | 122.00 | 125.00 |
| P-Value | 0.00 | 0.00 | 0.00 |
| $\chi^2$/df | 1.65 | 1.65 | 1.64 |
| CFA | 0.95 | 0.95 | 0.95 |
| TLI | 0.94 | 0.94 | 0.94 |
| SRMR | 0.05 | 0.05 | 0.05 |
| RMSEA | 0.06 | 0.06 | 0.06 |
| **Relative fit indices** | | | |
| **Satarro-Bentler chi square difference test** | | | |
| chi square difference (df=3) | | | 1.229 |
| p-value | | | 0.746 |

Source: Result of the authors' analysis, 2014

for a good fit model is < 3. The measurement model had a $\chi$2/df ratio of 1.65, indicating that the measurement model indeed had a good fit.

The comparative fit index (CFI) and Tucker-Lewis Index (TLI) were also used to examine the model fit. A model with CFI and TLI > 0.95 has a good fit. The measurement model had an acceptable fit because its CFI was 0.95 and TLI was 0.94. Moreover, standardised root mean square residual (SRMR) and root mean square error of approximation (RMSEA) were used to measure the misfit of the target model. The recommended cut-off values of SRMR and RMSEA are <0.05. The measurement model also had a good fit according to the misfit indices, with SRMR of 0.05 and RMSEA of 0.06. RMSEA was slightly higher than the cut-off value. Nonetheless, RMSEA < 0.08 is considered an acceptable fit.

The full CFA and measurement model results[1] cannot be shown here because of limited space. Based on the CFA results, all the latent variables had a high level of internal consistency because their composite reliability (CR) was greater than 0.70. They also had convergent validity because the standardised factor loadings of all the observed variables were statistically significant at the 1 percent level. Also, most standardised factor loadings were higher than 0.70, which is considered ideal. Only one standardised loading was less than 0.70 but higher than 0.50, and three of them were less than 0.50, but these observed variables were kept to retain the content validity of their latent variables.

***Theoretical structural model***

The theoretical structural model had the following fit indices: $\chi^2$/df = 1.65, CFI = 0.95, TLI = 0.94, SRMR = 0.05, RMSEA = 0.06. Hence, it had an acceptable fit, but several path coefficients were not statistically significant. The non-significant pathcoefficients were deleted to seek a simple model that fits the data well.

***Verified structural model***

The verified model also had a good fit ($\chi^2$/df = 1.64, CFI = 0.95, TLI = 0.94, SRMR = 0.05, RMSEA = 0.06). The Satorra-Bentler scaled chi square difference test was implemented to compare the theoretical model with the verified model. As presented in Table A1, Satarro-Bentler chi square difference was not significant, indicating that the verified model fits the sample data better than the theoretical model does. The verified model was selected as the final model.

**The results of analysis**

Figure A2 illustrates the structural paths of the verified model. The numbers in the parentheses are the statistically significant standardised coefficients of the direct effects. The statistically significant standardised coefficients of the indirect effects are shown in Table A2.

Figure A2: The verified model




Source: Result of the authors' analysis, 2014

Note: ( ) denotes standardised coefficients; significant at p-value <0.01*** and <0.05**.

1 The full CFA and measurement model results can be found in Ven (2017).

Table A2: Significant indirect effects

| H | Path | | | sc |
|---|---|---|---|---|
| | From | Via | To | |
| H11a | RPART | NRPART | PILO | 0.18** |
| H11b | RPART | NRPART | SUPPORT | 0.12** |
| H11c | RPART | NRPART PILO | SUPPORT | 0.06** |
| H13a | NRPART | PILO | SUPPORT | 0.07** |
| H13b | PILA | PILO | SUPPORT | 0.13** |

Source: Result of authors' analysis, 2014

Note: ** significant at p-value < 0.05.